ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

EAC
អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ៤៧៨-សណ.១៧អអក

ភ្នំពេញ, ថ្ងៃទី២៦ ខែ មិថុនា ឆ្នាំ២០១៧

**សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា**
**ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់លោកស្រី ឡុង គីមហេង សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកបន្ទាយស្រី ឃុំស្រែណូយ ស្រុកវ៉ារិន ផ្នែកខ្លះនៃឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប និងផ្នែកខ្លះនៃស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ**

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងស្រុកបន្ទាយស្រី ស្រុកវ៉ារិន ស្រុកស្វាយលើ ខេត្តសៀមរាប និងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាបណ្ណរួម (ផលិតកម្ម និងចែកចាយ) ឲ្យលោកស្រី ឡុង គីមហេង សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកបន្ទាយស្រី ឃុំស្រែណូយ ស្រុកវ៉ារិន ផ្នែកខ្លះនៃឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប និងផ្នែកខ្លះនៃស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ។ ពេលនេះ អាជ្ញាធរអគ្គិសនីកម្ពុជាបានអនុញ្ញាតឲ្យលោកស្រី ឡុង គីមហេង ទិញអគ្គិសនីពីអគ្គិសនីកម្ពុជា មកជំនួសឲ្យការផលិតដោយម៉ាស៊ីនផ្ទាល់ខ្លួន ។ ដោយឃើញថា នៅតំបន់ធ្វើសេវាកម្មរបស់លោកស្រី ឡុង គីមហេង លែងត្រូវការមធ្យោបាយផលិតកម្មទៀតហើយ ដូច្នេះ អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់លោកស្រី ឡុង គីមហេង ដោយប្តូរប្រភេទអាជ្ញាបណ្ណ ពីអាជ្ញាបណ្ណរួមមកអាជ្ញាបណ្ណចែកចាយវិញ តាមខ្លឹមសារដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជា អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់លោកស្រី ឡុង គីមហេង ដែលគ្រោងនឹងចេញនេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចនៅ......................................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅក្នុងស្រុកបន្ទាយស្រី ស្រុកវ៉ារិន ស្រុកស្វាយលើ ខេត្តសៀមរាប និងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោកស្រី ឡុង គីមហេង អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា " **អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ** "។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

បណ្ឌិត.ធី នរិន្ទ

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
**ទូរស័ព្ទ** : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ **ទូរសារ** : ០២៣ ២១៤ ១៤៤, **អ៊ីម៉ែល** : admin@eac.gov.kh ; Website : www.eac.gov.kh

សេចក្តីព្រាង

អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# សេចក្តីសម្រេចកែសម្រួលលើកទី៤
# លើឯកសារអាជ្ញាបណ្ណលេខ ២៤០ ឯអ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ សម្រាប់លោកស្រី ឡុង គីមហេង ផ្ញើសេវាកម្មអគ្គិសនី នៅផ្នែកខ្លះនៃស្រុកបន្ទាយស្រី ឃុំស្រែណូយ ស្រុកវ៉ារិន ផ្នែកខ្លះនៃ ឃុំកន្ទួត ស្រុកស្វាយលើ ខេត្តសៀមរាប និងផ្នែកខ្លះនៃ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

## សម្រាប់ការប្តូរប្រភេទអាជ្ញាបណ្ណពីអាជ្ញាបណ្ណរួម មកអាជ្ញាបណ្ណចែកចាយ

# DECISION ON THE FOURTH REVISION

TO THE LICENSE DOCUMENT No.240 LD DATED MAY 21, 2009 OF MRS. LONG KIMHENG FOR PROVIDING ELECTRIC POWER SERVICE AT SOME PART OF BANTEAY SREI DISTRICT, KHUM SRE NOY, VARIN DISTRICT, SOME PART OF KHUM KANTUOT, SVAY LEU DISTRICT, SIEM REAP PROVINCE AND SOME PART OF ANLONG VENG DISTRICT, ODDOR MEANCHEY PROVINCE

## FOR CHANGING THE TYPE OF LICENSE FROM CONSOLIDATED LICENSE TO DISTRIBUTION LICENSE

ថ្ងៃទី...      ខែ...      ឆ្នាំ២០១៧

..., 2017